# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយកក្រសួងអប់រំ*


ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧

ជូនចំពោះ មាតាបិតា/អាណាព្យាបាលះ

ប៉ុន្មានសប្តាហ៍ថ្មីៗនេះ មានសិស្សប្រមូលគ្នាជាក្រុមធំៗនៅកណ្តាលទីក្រុង និងតាមចំណតយានជំនិះ ក្រោយម៉ោងសិក្សា ដែលបណ្តាលឲ្យមានឧប្បត្តិហេតុនៃអំពើហិង្សា និងខុសសណ្តាប់ធ្នាប់។ ដើម្បីធ្វើយ៉ាណាឲ្យកូនរបស់លោកមានសន្តិសុខ និងសន្តិសុខរបស់អ្នកដទៃ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា នាយកដ្ឋានប៉ូលីសនៃទីក្រុងហ្វីឡាដែលហ្វ្យា និងប៉ូលីសរបស់ សិពតា (SEPTA) សុំឲ្យលោកអ្នកពិភាក្សាអំពីគ្រោះថ្នាក់នៃការដើរព្រែតត្រែតដែលគ្មានគោលដៅជាមួយក្រុមធំៗទាំងនេះ។

ទោះជាយុវវ័យដែលចូលរួមក្នុងសកម្មភាពខុសសណ្តាប់ធ្នាប់ និងបទឧក្រិដ្ឋ ជាសិស្សរបស់យើងតែមួយចំនួនតូចក៏ដោយ វាបង្ហាញឲ្យឃើញភាពអវិជ្ជមានចំពោះយុវវ័យទាំងអស់ ដែលរស់នៅក្នុងទីក្រុង។ សិស្សមួយចំនួនត្រូវគេចាប់ខ្លួនដោយសារធ្វើខុសសណ្តាប់ធ្នាប់ ហើយសិស្សដទៃទៀតមានរបួស។

ច្បាប់របស់ក្រសួងតម្រូវឲ្យសិស្សមានភាពគួរសម និងមានការគោរព នៅពេលធ្វើដំណើរទៅ និងមក ពីសាលា និងនៅពេលជិះរថយន្តដែលផ្តល់ឲ្យដោយក្រសួង។ សូមជ្រាបថា បើសិនជាចរិយាមាយាទរបស់កូនលោកអ្នក ត្រូវគេសម្រេចថាខុសសណ្តាប់ធ្នាប់ នៅពេលប្រើប័ណ្ណជិះរថយន្ត វានឹងបណ្តាលឲ្យគេដកសិទ្ធិប្រើប័ណ្ណជិះរថយន្ត សិពតា ពីកូនរបស់លោកអ្នក។ បើសិនជាគេដកហូតប័ណ្ណជិះរថយន្តពីកូន មាតាបិតាត្រូវដឹកកូនទៅ និងមកពីរៀន។ សិស្សានុសិស្សដែលត្រូវគេដកហូតប័ណ្ណជិះរថយន្ត ត្រូវមករៀនជារៀងរាល់ថ្ងៃ និងទាន់ពេលវេលា។ ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស គឺសម្រាប់សិស្សទាំងអស់ នៅពេលធ្វើដំណើរទៅ និងមកពីសាលា និងតាមរថយន្តក្រុងគ្រប់ប្រភេទ។ សិស្សដែលល្មើសនឹងក្រមសីលធម៌នេះ អាចទទួលការដាក់ទណ្ឌកម្មបន្ថែម។

យើងខ្ញុំសុំឲ្យលោកអ្នកបញ្ជាក់ពីសារៈសំខាន់នៃការធ្វើខ្លួនឲ្យបានត្រឹមត្រូវ និងជាតំណាងឲ្យសហគមន៍សាលាឲ្យបានល្អ គ្រប់ពេលវេលា។ យើងខ្ញុំសុំឲ្យសិស្សជៀសវាងសកម្មភាពដែលគ្មានសុវត្ថិភាព។

នៅពេលអាកាសធាតុកាន់តែក្តៅ ប៉ូលីសនឹងបង្ហាញខ្លួននៅកណ្តាលទីក្រុង និងពាសពេញទីក្រុង ដើម្បីធ្វើយ៉ាងណាឲ្យសិស្ស និងអ្នកដទៃទៀត មានសន្តិសុខ។ យើងខ្ញុំចង់ឲ្យពលរដ្ឋ និងភ្ញៀវទេសចរ ទាំងអស់ដឹងថាសិស្សរបស់យើងជាសិស្សល្អ គ្រប់ពេលវេលា ទាំងនៅក្នុង និងក្រៅសាលា។ សូមជួយយើងខ្ញុំឲ្យមានអ្វីៗទាំងនេះកើតមានឡើងដូចបំណង។

សូមអរគុណទុកជាមុន ចំពោះជំនួយ និងការគាំទ្រ របស់លោកអ្នក។

ដោយសេចក្តីស្មោះត្រង់



William R. Hite, Jr., Ed.D.